Tue Nov 11 2014 10:14:21 GMT+0700 (SE Asia Standard Time)

Login - Register | FOLLOW US ON




HOME ព័ត៌មានជាតិ សេដ្ឋកិច្ច អន្តរជាតិ ជីវិតកម្សាន្ត កីឡា LIFT MULTIMEDIA របាយការណ៍ពិសេស ប៉ុស្តិ៍អចលនទ្រព្យ កម្ពុជាចុងសប្តាហ៍ ដំណឹងជ្រើសរើសបុគ្គលិក

# សមត្ថកិច្ចនៅតែបន្តតាមរកតំណាងកម្មកររោងចក្រ ជូហ៊្វយ ដែលគេចខ្លួន

Tue, 11 November 2014 មុំ គន្ធា

**កំពង់ចាម:** សមត្ថកិច្ច ស្រុកជើងព្រៃ ខេត្តកំពង់ចាម នៅតែបន្តតាមរកតំណាងកម្មករដែលត្រូវចោទថា ជាអ្នកញុះញង់បង្កហិង្សានៅក្នុងការតវ៉ានៅមុខរោងចក្រ ជូហ៊្វយ កាលពីចុង ខែតុលា ដែលធ្វើឲ្យសមត្ថកិច្ចនិងកម្មកររងរបួសធ្ងន់-ស្រាល និងមានកម្មករ ១០ នាក់ត្រូវបានចាប់ខ្លួនឃុំផង។

លោក ហេង វុទ្ធី អធិការ ស្រុកជើងព្រៃ កាលពីម្សិលមិញបានឲ្យដឹងថា នីតិវិធីនៅតែបន្តតាមរកតំណាងកម្មករទាំងនោះដដែល ព្រោះពួកគេជាមេខ្លោងញុះញង់ឲ្យមានហិង្សាកើតឡើង។

លោក វុទ្ធី ថ្លែងថា៖ «វាជាបទល្មើសជាក់ស្តែងយើងមានភ័ស្តុតាង មិនមានអ្វីនៅសង្ស័យ មានពិរុទ្ធភាពដែលអាចធ្វើឲ្យយើងចាត់ការតាមផ្លូវច្បាប់បាន»។

លោក ហេង វុទ្ធី បានបន្តដោយចោទជាសំណួរថា តើអ្នកដែលគេចខ្លួនដឹងអត់ថា ពួកគេបានប្រព្រឹត្តខុស បើមិនបានធ្វើអីខុស ហេតុអីចាំបាច់នាំគ្នារត់គេចពីសមត្ថកិច្ច?

លោក ហេង វុទ្ធី បន្តថា៖ «ពួកគេគួរតែចេញមកធ្វើការសម្របសម្រួល ធ្វើការសុំទោស ឬធ្វើអ្វីមួយតាមដែលអាចធ្វើបាន ដើម្បីបញ្ចប់បញ្ហានេះ។ ការដែលពួកគេរត់គេចនេះ មិនមែនរួចខ្លួនមួយជីវិតទេ ច្បាប់នៅតែជាច្បាប់»។

លោក វុទ្ធី បញ្ជាក់ថា លោកគ្មានដីកាចាប់ខ្លួនទេ តែលោកមានដីកាកោះហៅ ពួកគេដឹងហើយ តែពួកគេមិនបានទទួលដីកាទេ។ តែសមត្ថកិច្ចនៅបន្តដាក់កម្លាំងតាមផ្ទះពួកគេរហូត។

តំណាងកម្មករមួយរូប អ្នកនាង ខាន់ កូឡាប អាយុ ៣៦ឆ្នាំ ដែលនៅលាក់ខ្លួនពីភ្នែកសមត្ថកិច្ចប្រាប់ ភ្នំពេញ ប៉ុស្តិ៍ តាមទូរស័ព្ទកាលពីម្សិលមិញថា អ្នកនាងនៅបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ហើយនាងនឹងត្រឡប់មកផ្ទះវិញ ប្រសិនបើសមត្ថកិច្ច ឬសហជីពធានាអះអាងពីសុវត្ថិភាពគាត់។

អ្នកនាង ខាន់ កូឡាប និយាយថា៖ «កម្មករដែលនៅតែបន្តការតវ៉ាបានប្រាប់ខ្ញុំថា សមត្ថកិច្ចមានការគុំកួនជាមួយខ្ញុំខ្លាំងណាស់ ដោយសារគេឃើញខ្ញុំចេញមុខការពារកម្មករខ្លាំងជាងគេ ប៉ុន្តែ អ្វីដែលយើងធ្វើ គឺគ្រាន់តែទាមទារសិទ្ធិសេរីភាពជូនកម្មករប៉ុណ្ណោះ»។

អ្នកនាងបន្តថា អ្នកនាងមិនបានធ្វើអ្វីខុសទេ។

លោក ប៉ិត ប៊ុនឈាន មន្ត្រីច្បាប់នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានឲ្យដឹងដែរថា លោកបានព្យាយាមធ្វើការពន្យល់តំណាងកម្មករដែលនៅតែបន្តធ្វើការលាក់ខ្លួនដោយប្រាប់ថា សមត្ថកិច្ចនឹងមិនចាប់ខ្លួនទេ គឺគ្រាន់តែកោះហៅសាកសួរតែប៉ុណ្ណោះ ប៉ុន្តែ ពួកគេនៅតែបារម្ភខ្លាចមានការចាប់ខ្លួនដដែល។

លោកប្រាប់ថា៖ «ពួកគេនៅមានការបាក់ស្មារតីដោយសារសមត្ថកិច្ចច្រើនប្រើខុសនីតិវិធីច្បាប់។ ទាំងនេះជាការព្រួយបារម្ភរបស់គាត់»។

លោក ប៊ុនឈាន បន្តទៀតថា មកដល់ពេលនេះមានបួននាក់ទៀតដែលនៅបន្តលាក់ខ្លួននៅឡើយ ដែលពួកគាត់ជាប្រធាន លេខា និងទីប្រឹក្សាសហជីពប្រចាំរោងចក្រ ជូហ៊្វយ។

កាលពីព្រឹកថ្ងៃចន្ទ កម្មករនៅតែបន្តធ្វើការជួបជុំគ្នានៅខាងមុខរោងចក្រ ជូហ៊្វយ ហើយការជួបជុំនេះនឹងបន្តនៅថ្ងៃអង្គារទៀត រង់ចាំមើលនីតិវិធីរបស់តុលាការថា នឹងមានការដោះលែងអ្នកជាប់ឃុំទាំង ៥ នាក់ដែរឬយ៉ាងណា?

លោក ប៊ុនឈាន បញ្ជាក់ថា៖ «ប្រសិនបើនៅតែមានដំណើរការណាមួយមិនសូវល្អសម្រាប់អ្នកជាប់ឃុំទាំង ៥ នាក់នេះ នោះយើងនឹងធ្វើការប្តូរទិសដៅដោយធ្វើដំណើរទៅកាន់តុលាការតែម្តង»។

លោក គីម សុជាតិ មេធាវីការពារក្តីមនុស្ស ៥ នាក់ដែលកំពុងតែជាប់ឃុំបានដាក់លិខិតទៅតុលាការ ខេត្តកំពង់ចាម កាលពីមុនបុណ្យអុំទូក ដោយស្នើសុំដោះលែងកូនក្តីលោកឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ប៉ុន្តែលោកមិនទាន់បានទទួលការឆ្លើយតបទេ។

## ព័ត៌មានពាក់ព័ន្ធ

- តុលាការសម្រេចឃុំខ្លួនកម្មករតវ៉ានៅកំពង់ចាម ៥នាក់
- ឃាត់ខ្លួនក្រុមយុទ្ធនាការសម្លៀកបំពាក់ស្អាត ៥ នាក់
- កម្មករ ម៉ារូឈុន៧នាក់របួសដោយប៉ះទង្គិចជាមួយប៉ូលិស
- មន្ត្រីសហជីពពីរនាក់ថា ត្រូវបានឃាត់ខ្លួនក្នុងកូដកម្មនៅរោងចក្រ Cambo
- សហជីពចោទពីការប៉ងចាប់ខ្លួនសកម្មជនតែសមត្ថកិច្ចបដិសេធ
- កម្មកររោងចក្រ Nex-T រងរបួសក្នុងការប៉ះទង្គិចគ្នាចុងសប្តាហ៍
- ជា មុនីគំរាមធ្វើកូដកម្មបើមិនលែងកម្មករ ៨ នាក់
- កម្មកររោងចក្រ Jiun Ye នៅ កំពង់ឆ្នាំង ធ្វើបាតុកម្មបិទផ្លូវ ៤ ម៉ោង




## វីឌីអូថ្មីបំផុត



### ពន្លឺភ្លើងពណ៌និងថាមពល នៃព្រះរាជពិធីបុណ្យអុំទូកត្រឡប់មកវិញ

បួនឆ្នាំបន្ទាប់ពីមានសោកនាដកម្មនៅលើស្ពានកោះពេជ្រ ហើយបន្ទាប់ពីពិធីបុណ្យអុំទូកនេះបានលុបចោល ៣ឆ្នាំជាប់ៗគ្នា ពន្លឺភ្លើងពណ៌និងថាមពល នៃពិធីបុណ្យនេះបានវិលត្រឡប់មកតាមផ្លូវ និងមាត់ទន



### ខួប ២៣ ឆ្នាំនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស

ទិដ្ឋភាពដង្ហែក្បួនដាក់ញត្តិរបស់ព្រះសង្ឃ អង្គការសមាគមខ្មែរកម្ពុជាក្រោម យុវជន សហជីព កម្មករ សហគមន៍រងគ្រោះដោយបញ្ហាដីធ្លី...និងមន្ត្រីអង្គការសង្គមស៊ីវិល ក្នុងពិធីរំឭកខួប២៣ឆ្នាំ នៃកិច្ចព្រមព្រៀងសន្តិភាព



លោកនិយាយកាលពីម្សិលមិញថា លោកកំពុងតែរង់ចាំមើលការសម្រេចរបស់តុលាការ ហើយលោកសង្ឃឹមថា កូនក្ដីលោកនឹងត្រូវបានដោះលែង។

សូមបញ្ជាក់ថា កាលពីចុង ខែតុលា កន្លងទៅកម្មករនៅរោងចក្រ ជូហ៊្វយ ប្រមាណរាប់រយនាក់បានផ្ទុះការតវ៉ារហូតឈានដល់មានអំពើហិង្សារវាងកម្មករ និងសមត្ថកិច្ច ដែលធ្វើឲ្យមានអ្នករងរបួសទាំងសងខាង។ ក្នុងនោះដែរ ក៏មានមនុស្ស ១០ នាក់ត្រូវបានសមត្ថកិច្ចនគរបាលចាប់ឃាត់ខ្លួនធ្វើការសាកសួរនៅតុលាការខេត្តផងដែរ តែបន្ទាប់មកមានកម្មករ ៥ នាក់ត្រូវបានដោះលែងវិញ ដោយពួកគេមិនមានកំហុស ចំណែក ៥ នាក់ផ្សេងទៀតត្រូវបានតុលាការបានសម្រេចធ្វើការចោទនិងបន្តឃុំខ្លួន៕

0 Comments Please, login or register to post a comment

The Phnom Penh Post
ភ្នំពេញ ប៉ុស្តិ៍

Post Media Co Ltd
888 Building F, 8th Floor, Phnom Penh Center
Corner Sothearos & Sihanoulk Blvd
Sangkat Tonle Bassac
12301 Phnom Penh
Cambodia

Tel: +855(0) 23 214 3 11-17
Fax: +855(0) 23 214 318

Company

Staff list

Sections

ព័ត៌មានជាតិ

Facebook Twitter Google +

7D SEVENDAYS

LIFT THE ESSENTIAL MAGAZINE FOR CAMBODIAN YOUTH.

Copyright © 2013 The Phnom Penh Post. All Rights Reserved. Web design by IConsulting